www.kidworship.kr

# ចំណងជើង៖ កូនពៅវង្វេង



68Page

**Narration** មានឪពុកនិងកូនប្រុសពីរនាក់បានរស់នៅជាមួយនឹងគ្នានៅក្នុងភូមិតូចមួយ។ឪពុកបានស្រ
ឡាញ់ទៅដល់កូនប្រុសរបស់គាត់ទាំងពីរខ្លាំងណាស់
។កូនប្រុសច្បងគឺជាកូនដែលស្តាប់បង្គាប់ទៅដល់ឪពុក
ប៉ុន្តែកូនប្រុសពៅវិញគឺជាកូនដែលចូលចិត្តលេង និងបង្កបញ្ហា។
នៅថ្ងៃមួយកូនប្រុសពៅបានសម្រេចចិត្តចង់ចាកចេញពីផ្ទះរបស់ឪពុកគាត់
ដើម្បីទៅរស់នៅដោយខ្លួនឯង ដោយសារគាត់គិតថាពេលធ្វើបែបនេះ
គាត់អាចធ្វើអ្វីគ្រប់យ៉ាងបានតាមតែចិត្តគាត់ចង់ធ្វើ។

**កូនប្រុសពៅ** លោកឪពុក! សូមលោកឪពុកចែកមរតកឲ្យខ្ញុំមក ខ្ញុំចង់ចេញពីទីនេះ
ហើយរស់នៅដោយខ្លួនរបស់ខ្ញុំ។

**ឪពុក** ថាម៉េច? កូនប្រុស!! ពិភពលោកនេះ គឺជាទីកន្លែងដែលពិបាករស់នៅខ្លាំងណាស់។
ហេតុអ្វីបានជាកូនមិនគិតពិចារណាពីរឿងនេះឲ្យច្បាស់បន្តិចទៀតទៅ?

**កូនប្រុសពៅ** លោកឪពុកខ្ញុំមិនមែនជាកូនក្មេងទៀតទេ!! ខ្ញុំធំហើយ
ហើយខ្ញុំក៏អាចរស់នៅដោយខ្លួនរបស់ខ្ញុំបាន។

**Narration** ទោះជាយ៉ាងណាក៏ដោយក៏លោកឪពុកមានអារម្មណ៍ថាពិតជាសោកស្តាយ
ព្រោះកូនប្រុសរបស់គាត់ចង់ចាកចេញពីគាត់។
គាត់បានចែកទ្រព្យសម្បត្តិរបស់គាត់ជាពីរចំណែកសំរាប់កូនប្រុសទាំងពីររបស់គាត់។
ហើយឪពុកបានឲ្យទៅកូនប្រុសពៅនូវអ្វីដែលគេចង់បាន។

---



69Page

**Narration** មិនយូរប៉ុន្មាន កូនប្រុសពៅក៏បានចាកចេញពីផ្ទះរបស់ឪពុក
ហើយនាំយកមរតកដែលជាចំណែករបស់គាត់ទៅ។ គាត់បានស្នាក់នៅក្នុងទីក្រុងដ៏ធំមួយ
ដែលមានភាពស្រស់ស្អាត នៅទីនោះគាត់បានធ្វើអ្វីដែលគាត់ចូលចិត្ត
បរិភោគអ្វីដែលគាត់ចង់បរិភោគ ធ្វើអ្វីដែលគាត់ចង់ធ្វើ នឹងទិញអ្វីដែលគាត់ចង់ទិញ។

**កូនប្រុសពៅ** នេះវាពិតជាល្អណាស់!!ខ្ញុំអាចធ្វើអ្វីដែលខ្ញុំចង់ធ្វើ
!!បើដូច្នេះខ្ញុំគួរតែចេញពីផ្ទះរបស់ឪពុកខ្ញុំយូរណាស់មកហើយ។

**Narration** នៅរៀងរាល់យប់កូនប្រុសពៅតែងតែជួបជុំជាមួយនិងមិត្តភក្តិថ្មីរបស់គាត់
ហើយញ៉ាំអាហារនិងស្រាថ្លៃៗ
ហើយពួកគេបានទិញសំលៀកបំពាក់និងគ្រឿងអលង្ការពាក់ដូចជាព្រះអម្ចាស់។
ប៉ុន្តែនៅទីបំផុត ការខ្ជះខ្ជាយរបស់គាត់បានធ្វើឲ្យគាត់ធ្លាក់ខ្លួនទៅនៅក្នុងព្រៃ។

---



70Page

**Narration** នៅពេលដែលប្រាក់របស់គាត់បានចាយអស់
មិត្តភក្តិរបស់គាត់ក៏បានបាត់បង់អស់ទៅដែរ។ គាត់បានជួបនូវភាពខ្វះខាត
ហើយរស់នៅតែម្នាក់ឯង! កូនប្រុសពៅទ្រាំនឹងការស្រេកឃ្លានមិនបានទៀតទេ
គាត់ក៏បានទៅស៊ីឈ្នួលធ្វើការឲ្យចៅហ្វាយម្នាក់
ចៅហ្វាយនោះបាននិយាយទៅកាន់កូនប្រុសពៅថា៖

**Narration** អេរ! ឆាប់មកណេះ!! ធ្វើការឲ្យលឿនបន្តិចទៅមើល!! ឆាប់លាងទ្រុងជ្រូកនេះឲ្យស្អាតទៅ
រួចដាក់បាយឲ្យវាស៊ីផង...! អ៊ូក..អ៊ូកៗ....ឆាប់មកនេះ!

**កូនប្រុសពៅ** ហ៊ឹម....ពេលនេះខ្ញុំឃ្លានខ្លាំងណាស់ ខ្ញុំពិតជាចង់បរិភោគបាយជ្រូកនេះណាស់!
ដើម្បីចំអែតក្រពះរបស់ខ្ញុំ។

**Narration** កូនប្រុសពៅបានស្ថិតនៅក្នុងភាពអស់សង្ឃឹម
រំពេចនោះគាត់បាននឹកឃើញដល់ឪពុករបស់គាត់
គាត់ពិតជាចង់ទៅជួបឪពុករបស់គាត់ម្តងទៀតណាស់។

**កូនប្រុសពៅ** ឪពុករបស់ខ្ញុំគាត់តែងតែស្រឡាញ់ដល់ខ្ញុំ
ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ។ចំណែកឯបាវបំរើរបស់គាត់វិញ
គាត់តែងតែឲ្យពួកគេបានបរិភោគគ្រប់គ្រាន់។ប្រសិនបើខ្ញុំនៅតែបន្តរស់នៅបែបដូច្នេះ
នោះខ្ញុំនឹងស្រេកឃ្លានរហូតដល់ស្លាប់ជាមិនខាន។
ខ្ញុំនឹងត្រឡប់ទៅផ្ទះរបស់ឪពុករបស់ខ្ញុំវិញ ហើយសូមឲ្យគាត់បានលើកលែងទោសដល់ខ្ញុំ
ទោះបីជាគាត់ចាត់ទុកខ្ញុំត្រឹមជាអ្នកបំរើក៏បានដែរ។

.....................................................................................................

**Narration** ដូច្នេះកូនប្រុសពៅក៏បានត្រឡប់ទៅផ្ទះរបស់ឪពុកគាត់នៅឯស្រុកកំណើតវិញ
ប៉ុន្តែនៅពេលដែលគាត់បានត្រឡប់ទៅជិតដល់ផ្ទះរបស់ឪពុកគាត់
គាត់មានការព្រួយបារម្ភណ៍និងរន្ធត់ចិត្តជាខ្លាំង។

**កូនប្រុសពៅ** តើឪពុករបស់ខ្ញុំអាចនឹងលើកលែងទោសដល់ខ្ញុំដែរ ឬទេ?
ខ្ញុំបានចាយបំផ្លាញទ្រព្យសម្បត្តិរបស់លោកឪពុកអស់ហើយ
រួចបានត្រឡប់មកក្នុងស្ថានភាពជាអ្នកសូមទាន !!
ហ៊ឹម....វាពិតជាគ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ
ដែលគាត់មិនព្រមលើកលែងទោសសំរាប់ខ្ញុំនោះ ប៉ុន្តែតើអ្វីដែលខ្ញុំត្រូវធ្វើបន្តទៀត?

**Narration** កូនប្រុសពៅបានឃំដើរឆ្ពោះទៅកាន់ផ្ទះរបស់ឪពុកគាត់
ពេលនោះកូនប្រុសពៅបានមើលឃើញឪពុករបស់គាត់កំពុងតែឈរនៅមាត់ទ្វា។
ឪពុកតែងតែរងចាំផ្លូវរបស់កូនប្រុសគាត់រៀងរាល់ថ្ងៃ
ចាប់តាំងពីថ្ងៃដែលកូនប្រុសរបស់គាត់បានចាកចេញពីផ្ទះទៅ។
ភ្លាមៗនោះគាត់បានឃើញកូនប្រុសរបស់គាត់ ឪពុកបានរត់ទៅកាន់កូន
ហើយឱបកូនប្រុសយ៉ាងណែន។


71Page


72Page

**កូនប្រុសពៅ** លោកឪពុក! កូនពិតជាបានប្រព្រឹត្តអំពើបាបច្រើនណាស់។
កូនមិនសាកសមនឹងហៅជាកូនរបស់លោកឪពុកទៀតទេ។
សូមឲ្យខ្ញុំបានក្លាយទៅជាអ្នកបំរើរបស់លោកឪពុកម្នាក់ផង។

**ឪពុក** កូនប្រុសសម្លាញ់! វាមិនល្អទេបើដូច្នោះនោះ ពុកបានរង់ចាំកូនជារៀងរាល់ថ្ងៃ។
កូនសម្លាញ់! ពុកស្រឡាញ់កូន ទោះបីជាពេលមុន
ឬក៏ឥឡូវនេះក៏ដោយពុកនៅតែស្រឡាញ់កូន។ កូនគឺជាកូនសម្លាញ់របស់ពុក។



73Page

**Narration** ឪពុកបានហៅអ្នកបំរើរបស់គាត់។

**ឪពុក** ចូរទៅយកសំលៀកបំពាក់ដែលល្អបំផុតមកពាក់ឲ្យកូនរបស់ខ្ញុំជាប្រញ៉ាប់
ហើយយកជញ្ជៀន និងស្បែកជើងមកពាក់ឲ្យផង
រួចយកគោដែលយើងបានបំប៉នទុកមកកាប់ជប់លៀងឲ្យសប្បាយចុះ។

**Narration** ឪពុកបានរៀបចំពិធីជប់លៀងមួយយ៉ាងធំ
សំរាប់ការដែលកូនប្រុសពៅរបស់គាត់បានត្រឡប់មកវិញ។
ជាចុងក្រោយកូនប្រុសពៅបានយល់ពីសេចក្តីស្រឡាញ់របស់ឪពុក
ដែលជាក្តីស្រឡាញ់ដែលមិនចេះសាបសូន្យ។